**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

ថ្ងៃ.សុក្រ.៨.រោច.ខែ.កត្តិក.....ឆ្នាំ.ច.សំរឹទ្ធិ.ស័ក ព.ស.២៥៦២

លេខៈ..៩០..សជណ....

រាជធានីភ្នំពេញ ថ្ងៃទី.៣០...ខែ.វិច្ឆិកា....ឆ្នាំ ២០១៨

## សេចក្តីជូនដំណឹង
## ស្តីពីការដេញថ្លៃការងារជួសជុលរោងសម្តែងសាលាមធ្យមវចិត្រសិល្បៈ

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក(គិតទាំងសហគ្រាស ឯកត្តបុគ្គល) និងក្រុមហ៊ុនបរទេសទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវ ក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យបានជ្រាបថាៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈលើការងារជួសជុលរោងសម្តែងសាលាមធ្យមវិចិត្រសិល្បៈ ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម ស្ថិតនៅអគារលេខ២២៧ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃពុធ ៦រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៨ខែវិច្ឆិកា ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ ។ ប្រាក់ទិញឯកសារដេញថ្លៃ មិនអាចបង្វិលជូនវិញបានឡើយ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃព្រហស្បតិ៍ ៥រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង៩:០០ នាទី។ រាល់សំណើដេញថ្លៃដែលដាក់ក្រោយកាលបរិច្ឆេទកំណត់ នឹងត្រូវបដិសេធ។

សំណើដេញថ្លៃ នឹងត្រូវបើកជាសាធារណៈ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)នៅអង្គភាពលទ្ធកម្ម តាមអាស័យដ្ឋានខាងលើ និងត្រូវបើកនៅថ្ងៃព្រហស្បតិ៍ ៥រោច ខែមិគសិរ ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង៩:០០ នាទីជាកំហិត និងដោយមានវត្តមានចូលរួមពីក្រុមហ៊ុនផ្គត់ផ្គង់ ឬតំណាងស្របច្បាប់ ។

សំណើដេញថ្លៃ ត្រូវភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ ចំនួន០២ភាគរយ ចេញដោយអគ្គនាយដ្ឋានរតនាគារជាតិ ឬធនាគារពាណិជ្ជដៃគូ ដូចមានរៀបរាប់នៅក្នុងសេចក្តីណែនាំចំពោះអ្នកដេញថ្លៃ ហើយទឹកប្រាក់ដែលត្រូវកក់សម្រាប់ធានាការដេញថ្លៃ ចំនួន៤៩ ៣០០ ០០០រៀល(សែសិបប្រាំបួនលាន បីរយពាន់រៀលគត់)។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

បានពិនិត្យត្រឹមត្រូវ

សូមទាក់ទង: ០៨៥ ៦២៦ ៧៨៣

ចម្លងជូន:
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ"
- អង្គភាពប្រឆាំងអំពើពុករលួយ

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ភឿង-សកុណា**